ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

ភ្នំពេញ ថ្ងៃទី ៤០ ខែ ឧសភា ឆ្នាំ ២០១៦

លេខៈ ០៨៦ កបទ.សអ.បល

# សេចក្តីជូនដំណឹង

សូមជូនដំណឹងដល់សាធារណជនឲ្យបានជ្រាបថា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នឹងរៀបចំការប្រឡងជ្រើសរើសមន្ត្រីក្របខណ្ឌថ្មី ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃ សៅរ៍ ទី ០៩ ខែ កក្កដា ឆ្នាំ ២០១៦ ចំនួន ២៦ នាក់ ដូចខាងក្រោម ៖

- ប្រភេទក្របខ័ណ្ឌ "ក" ចំនួន ២០ នាក់
  - ចំនួន ១៥ នាក់ ពីនិស្សិត
  - ចំនួន ០៥ នាក់ ពីមន្ត្រីរាជការ នៃក្រសួង-ស្ថាប័ននានា
- ប្រភេទក្របខ័ណ្ឌ "ខ" ចំនួន ០៦ នាក់ ពីនិស្សិត ។

បេក្ខជន-បេក្ខនារី ត្រូវមានលក្ខណៈសម្បត្តិដូចតទៅ ៖

១. ក្របខ័ណ្ឌ "ក" សញ្ញាបត្រចាប់ពី**បរិញ្ញាបត្រ**ឡើងទៅ និងក្របខ័ណ្ឌ "ខ" សញ្ញាបត្រចាប់ពី **បរិញ្ញាបត្ររង** (Bac II+២) ឡើងទៅ

២. មុខជំនាញ ៖ ទំនាក់ទំនងអន្តរជាតិ នីតិសាស្ត្រ សេដ្ឋកិច្ច ពាណិជ្ជសាស្ត្រ ព័ត៌មានវិទ្យា ភាសាអង់គ្លេស បារាំង ជប៉ុន កូរ៉េ ចិន ឡាវ ថៃ វៀតណាម និងជំនាញផ្សេងៗទៀត

៣. សញ្ជាតិខ្មែរ និង សុខភាពល្អ

៤. អាយុក្រោម ៖ ៣០ ឆ្នាំ សម្រាប់និស្សិត និង ៤៥ ឆ្នាំ សម្រាប់មន្ត្រីរាជការ គិតត្រឹមថ្ងៃប្រឡង

៥. ចំណេះដឹងភាសាច្បាស់លាស់ ៖ អង់គ្លេស បារាំង ជប៉ុន កូរ៉េ ចិន ឡាវ ថៃ ឬ វៀតណាម

៦. ជនពិការ ដែលមានសមត្ថភាពសមស្រប និងបេក្ខនារីត្រូវបានលើកទឹកចិត្ត ។

បញ្ជាក់ ៖ - សញ្ញាបត្រពីក្រៅប្រទេស ត្រូវបញ្ជាក់ពីនាយកដ្ឋានឧត្តមសិក្សា
- សញ្ញាបត្រក្នុងប្រទេស ត្រូវបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន
- បេក្ខជន-នារី ត្រូវបំពេញសំណុំបែបបទ ៖ ពាក្យសុំចុះឈ្មោះប្រឡងជ្រើសរើសមន្ត្រី ចំនួន ០១ ច្បាប់ ជីវប្រវត្តិសង្ខេប ចំនួន ០១ ច្បាប់ សលាកប័ត្រឯកត្តជន ០១ ច្បាប់ និងបង្កាន់ដៃបង់ប្រាក់សុំសិទ្ធិប្រឡងង ចំនួន ០១ ច្បាប់

វិញ្ញាសាប្រឡង ៖

- វិញ្ញាសាសរសេរ : ភាសាអង់គ្លេស បារាំង ជប៉ុន កូរ៉េ ចិន ឡាវ ថៃ ឬ វៀតណាម
- វិញ្ញាសាសួរផ្ទាល់មាត់ : ភាសាអង់គ្លេស បារាំង ជប៉ុន កូរ៉េ ចិន ឡាវ ថៃ ឬ វៀតណាម ។

សាធារណជន ដែលមានបំណងចូលរួមការប្រឡង សូមទាញយក និងបំពេញសំណុំបែបបទសុំសិទ្ធិប្រឡងតាមរយៈគេហទំព័រ www.mfaic.gov.kh និងទំព័រហ្វេសប៊ុក www.facebook.com/mfaic.gov.kh ។

ការទទួលពាក្យ នឹងត្រូវចាប់ផ្តើមពីថ្ងៃទី **១៦ ខែ ឧសភា** រហូតដល់ថ្ងៃទី **១៦ ខែ មិថុនា ឆ្នាំ ២០១៦** រៀងរាល់ម៉ោងធ្វើការ នៅនាយកដ្ឋានបុគ្គលិក នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលមានអាសយដ្ឋានលេខ ៣ វិថី **សម្តេច ហ៊ុន សែន** សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**ជ. រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**អ៊ុច បូរិទ្ធ**

<u>ចម្លងជូន:</u>
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

## បទបញ្ញត្តិទូទៅ
## សម្រាប់បេក្ខជន បេក្ខនារី ប្រឡងចូលបំរើការងារជាមន្ត្រីក្របខណ្ឌថ្មី ២៦ នាក់
## នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
## នៅថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១៦

ដើម្បីរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ និងវិន័យ បេក្ខជន-បេក្ខនារី ចូលរួមប្រឡងជ្រើសរើសមន្ត្រីក្របខណ្ឌថ្មីឆ្នាំ ២០១៦ ត្រូវគោរពបទបញ្ញត្តិទូទៅ ដូចខាងក្រោម ៖

ក. ត្រូវ ៖

១. មកដល់មណ្ឌលប្រឡងមុនពេលដំណើរការនៃការប្រឡង
២. យកមកជាមួយនូវបង្កាន់ដៃ
៣. អង្គុយតាមលេខតុ ប្រគល់សន្លឹកកិច្ចការឲ្យមន្ត្រីអនុរក្សនៅពេលបញ្ចប់ម៉ោងប្រឡង ទោះបីកិច្ចការនោះធ្វើពុំចប់ក៏ដោយ
៤. ឲ្យមន្ត្រីអនុរក្សឆែក ឬដកហូតឯកសារដែលក្រសួងមិនអនុញ្ញាតឲ្យយកចូលក្នុងបន្ទប់ប្រឡង។

ខ. ហាម ៖

១. ចូលក្នុងបន្ទប់ប្រឡងមុនពេលមន្ត្រីអនុរក្សហៅឈ្មោះ
២. ស្លៀកពាក់ឯកសណ្ឋានកងកម្លាំងប្រដាប់អាវុធចូលក្នុងបន្ទប់ប្រឡង
៣. យកអាវុធ ជាតិផ្ទុះ ចូលក្នុងបន្ទប់ប្រឡង
៤. ប្រើពាក្យសំដី ឬអាកប្បកិរិយាមិនសមរម្យទៅលើគណៈមេប្រយោគ និងមន្ត្រីអនុរក្សនៅក្នុងបន្ទប់ប្រឡង
៥. សរសេរចម្លើយវិញ្ញាសានៅលើក្រដាសកិច្ចការ ដែលគ្មានហត្ថលេខារបស់មន្ត្រីអនុរក្ស
៦. ចម្លងសំណួរវិញ្ញាសាចូលក្នុងក្រដាសកិច្ចការផ្សេង ឬបោះសំណួរវិញ្ញាសាចេញក្រៅបន្ទប់ប្រឡង
៧. ដើបឈរ ងាកឆ្វេង-ស្តាំ ឬដើរចេញពីកន្លែងដោយគ្មានការអនុញ្ញាតពីមន្ត្រីអនុរក្ស

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

៨. ឡូឡា ឬទាញយកក្រដាសកិច្ចការរបស់អ្នកដទៃមកចម្លង

៩. ប្តូរគ្នានូវក្រដាសកិច្ចការ ក្រដាសព្រាង ផ្ទៀងផ្ទាត់ចម្លើយ ឬចម្លងគ្នា និងដាក់ក្រដាសកិច្ចការឆ្ងាយពីមុខរបស់ខ្លួន ដើម្បីឲ្យអ្នកដទៃមើល ឬទាញយកបានឡើយ

១០. សរសេរប៊ិចពណ៌ផ្សេងក្រៅពីប៊ិចពណ៌ខ្មៅនៅលើក្រដាសកិច្ចការ និងធ្វើសញ្ញាសម្គាល់លើក្រដាសកិច្ចការរបស់ខ្លួន ដូចជា: ការសរសេរអក្សរប្លែកពីតួអក្សរទាំងអស់ក្នុងកិច្ចការ ធ្វើសញ្ញាផ្សេងៗ ឬគូរបន្ទាត់ខុសប្រក្រតី

១១. លាក់ ឬហែកក្រដាសកិច្ចការរបស់ខ្លួន និងហែក ឬលាក់ក្រដាសកិច្ចការអ្នកដទៃ

១២. ធ្វើឲ្យខូចខាតសម្ភារៈនៅក្នុងបន្ទប់ប្រឡង

១៣. អ្នកដទៃប្រឡងជំនួស ឬសរសេរបំពេញបន្ថែមលើក្រដាសកិច្ចការរបស់ខ្លួនជាដាច់ខាត

១៤. បង្កសកម្មភាព ដែលនាំឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ និងរបៀបរៀបរយ នៃការប្រឡង។

ក្នុងករណីបេក្ខជន-បេក្ខនារីណាម្នាក់ បំពានចំណុចណាមួយដូចដែលមានចែងក្នុងបទប្បញ្ញតិខាងលើ ត្រូវចាត់ទុកថា បេក្ខជន-បេក្ខនារីនោះបោះបង់សិទ្ធិប្រឡង ។

ភ្នំពេញ ថ្ងៃទី 10 ខែ ឧសភា ឆ្នាំ ២០១៦

**ឋ. រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**អ៊ុច បូររិទ្ធ**